**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...០៥...ស.សរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការតែងតាំងសមាសភាពក្រុមវិភាគព័ត៌មាន**

***

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ/បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ/បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៨ ស្តីពីការបង្កើតក្រុមវិភាគព័ត៌មានរបស់ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ស ម្រេ ច**

**ប្រការ ១.**_ ត្រូវបានតែងតាំងក្រុមវិភាគព័ត៌មាននៃខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម | **ប្រាក់ សុខុន** | ប្រធាន |
| ២- | ឯកឧត្តម | **រស់ កុសល** | អនុប្រធាន |
| ៣- | ឯកឧត្តម | **ខ្លូង រតនា** | អ្នកស្រាវជ្រាវជាន់ខ្ពស់ |
| ៤- | ឯកឧត្តម | **ភាល ម៉ាភារី** | សមាជិក |
| ៥- | លោក | **ហ៊ុន ម៉ានី** | សមាជិក |
| ៦- | លោក | **អ៊ុក ដូរ៉ានី** | សមាជិក |

www.pheakdeylaw.com

៧- លោក **ប្រាក់ សោភ័ណ** សមាជិក

៨- លោក **ម៉ៅ មិត្យារុណ** សមាជិក

៩- លោក **លី សុខហេង** សមាជិក

១០- លោក **ទាន សំណាង** សមាជិក

១១- លោក **សាង បូរ៉ាណា** សមាជិក

**ប្រការ ២.**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀង១ខ្លួន ។

*រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ កុម្ភៈ ឆ្នាំ២០០៨*

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចក្នុងប្រការ ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

www.pheakdeylaw.com